# II. លទ្ធផលបំពេញការងារវិស័យអប់រំឆ្នាំ២០០៥

## ១. ធានាលទ្ធភាពទទួលសេវាអប់រំប្រកបដោយសមធម៌

ដើម្បីឈានទៅសម្រេចគោលនយោបាយធានាលទ្ធភាពទទួលសេវាអប់រំប្រកបដោយសមធម៌ ក្រសួងអប់រំ យុវជន និងកីឡាបានអនុវត្តនូវយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាពជាច្រើនរួមមាន:

- លុបបំបាត់វិភាគទានក្រៅផ្លូវការគ្រប់ប្រភេទរបស់មាតាបិតាសិស្ស
- គាំទ្រថវិកាសម្រាប់ដំណើរការសាលារៀន
- ពង្រឹងការងារគ្រប់គ្រងការរៀននិងបង្រៀន
- ផ្គត់ផ្គង់សៀវភៅសិក្សាដល់សិស្សដោយឥតគិតថ្លៃ
- ពង្រាយបុគ្គលិកឡើងវិញនិងផ្តល់រង្វាន់លើកទឹកចិត្តសម្រាប់ការបំពេញការងារល្អរបស់បុគ្គលិក
- បន្តធ្វើការអភិវឌ្ឍគ្រូបង្រៀននិង
- ផ្តល់អាហារូបករណ៍សម្រាប់សិស្សក្រីក្រពិសេសសិស្សស្រី ព្រមទាំងអនុវត្តកម្មវិធីចូលរៀនឡើងវិញ និង កម្មវិធីសមមូលសម្រាប់សិស្សបោះបង់ការសិក្សាជាដើម ។

ដោយឡែកលទ្ធផលដែលសម្រេចបានក្នុងរយៈពេលកន្លងមកនេះ មានបង្ហាញជូនលំអិតតាមផ្នែកជំនាញនីមួយៗ ដូចខាងក្រោម :

### ១.១. ការអប់រំកុមារតូច និង មត្តេយ្យសិក្សា

ក្នុងឆ្នាំសិក្សា២០០៤-២០០៥ សាលាមត្តេយ្យគ្រប់ប្រភេទសរុបមានចំនួន២,២២៣ ក្នុងនោះសាលាមត្តេយ្យសិក្សាសាធារណៈមានចំនួន១,៣៦៥ សាលាមត្តេយ្យសិក្សាឯកជនមានចំនួន៨០ និងសាលាមត្តេយ្យសិក្សាសហគមន៍មានចំនួន ៧៧៨ ។ ក្នុងចំនួនខាងលើនេះ សាលាមត្តេយ្យសិក្សាសាធារណៈដែលមានទីតាំងដាច់ដោយឡែកមានចំនួនតែ១២៩សាលាប៉ុណ្ណោះ ក្រៅពីនោះជាថ្នាក់រៀនមត្តេយ្យសិក្សាដែលនៅជាមួយសាលាបឋមសិក្សា ។ ដោយមានការខិតខំពីសំណាក់លោកគ្រូ អ្នកគ្រូមត្តេយ្យសិក្សា ការចូលរួមរបស់មាតាបិតាសិស្សនិងសហគមន៍ ការប្រមូលកុមារអោយចូលរៀននៅមត្តេយ្យសិក្សាទាំងបីកម្រិតបានចំនួន៧២,២១៤នាក់ ក្នុងនោះកុមារីមានចំនួន៣៦,១៥១នាក់ ។ បុគ្គលិកមត្តេយ្យសិក្សាសរុបមានចំនួន២,៨៣៣នាក់ ក្នុងនោះស្រីចំនួន២,៧៨៨នាក់ ។ ចំនួនបុគ្គលិកបង្រៀនមាន២,៦៥០នាក់ ក្នុងនោះស្រីមានចំនួន២,៦២៤នាក់ ។

ជារួមក្រសួងកំពុងជំរុញអោយខេត្ត-ក្រុងទូទាំងប្រទេស ខិតខំយកចិត្តទុកដាក់លើការងារមត្តេយ្យសិក្សាអោយដំណើរការបានកាន់តែខ្លាំងក្លាថែមទៀត ដោយហេតុថា តាមរយៈការសិក្សាស្រាវជ្រាវនិងបទពិសោធន៍ជាទូទៅបង្ហាញថា កុមារដែលបានឆ្លងកាត់ការរៀនសូត្រនៅតាមមត្តេយ្យសិក្សា អាចបន្តការសិក្សាបានវែងឆ្ងាយជាងកុមារដែលមិនឆ្លងមត្តេយ្យសាលា ។




ទន្ទឹមនឹងការរីកចម្រើនរបស់ផ្នែកមត្តេយ្យសិក្សា ក្រសួងបានយកចិត្តទុកដាក់ដល់ការអប់រំកុមារតូច តាមរយៈការបង្កើតរចនាសម្ព័ន្ធគ្រប់គ្រងដែលពុំធ្លាប់មានពីមុនមក ។ ក្រសួងបានពិនិត្យឃើញថាកុមារអាយុ៥ឆ្នាំបានចូលរៀនប្រមាណតែ២០%ប៉ុណ្ណោះ ។ តាមរយៈកម្មវិធីអប់រំកុមារតូចតាមផ្ទះ កុមារតូចទាំងអស់បានទទួលការគាំពារចិញ្ចឹមបីបាច់ថែរក្សាគ្រប់គ្រាន់ ហើយឪពុកម្តាយមានសមត្ថភាពក្នុងការគាំពារចិញ្ចឹមបីបាច់ថែរក្សាអប់រំកូន ។ កម្មវិធីនេះមិនត្រឹមតែចូលរួមចំណែកអនុវត្តសិទ្ធិកុមារប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងកាត់បន្ថយអំពើហឹង្សាក្នុងគ្រួសារ ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ការរីករាលដាលជំងឺអេដស៍ គ្រឿងញៀន និងសមាសធាតុអសកម្មផ្សេងៗទៀតក្នុងសង្គមផងដែរ ។ ហេតុដូច្នេះហើយទើបក្រសួងខិតខំចលនាធនធានពីគ្រប់ផ្នែករួមមានសហគមន៍មូលដ្ឋាន អង្គការអន្តរជាតិនានា អង្គការក្រៅរដ្ឋាភិបាលអោយជួយគាំទ្រការងារអប់រំកុមារតូចតាមសហគមន៍មូលដ្ឋាននិងតាមខ្នងផ្ទះ ដើម្បីរួមចំណែកជួយដល់រាជរដ្ឋាភិបាលដែលកំពុងជួបប្រទះការខ្វះខាតផ្នែកថវិកា និងកំពុងដោះស្រាយការងារជាអាទិភាពជាច្រើនទៀតក្នុងកាលៈទេសៈចំពោះមុខនេះ ។

## ១.២. បឋមសិក្សា

តាមរបាយការណ៍ស្ថិតិឆ្នាំសិក្សា២០០៤-០៥ សាលារៀនបឋមសិក្សាសរុបទូរទាំងប្រទេសមានចំនួន៦,១៨០ ។ សិស្សសរុបមានចំនួន២,៦៨២,១២៩នាក់ ក្នុងនោះសិស្សស្រីមានចំនួន១,២៦៦,៤២០នាក់ ស្មើនឹង៤៧%នៃចំនួនសិស្ស សរុប ឬអាចនិយាយបានថា គំលាតយេនឌ័រនៅបឋមសិក្សាមានតិចតួចប៉ុណ្ណោះ ហើយកុមារដល់វ័យសិក្សាមានលទ្ធភាពចូលរៀនដូចៗគ្នា ។ ចំនួនបុគ្គលិកសាលាបឋមសិក្សាមាន ៦០,៨៤១នាក់ (នារីមាន ២២,៩៣៤នាក់) ក្នុងចំនួននោះបុគ្គលិកបង្រៀនមាន ៥០,១៤០នាក់ (នារីមាន ២០,៦៧៨នាក់ ឬស្មើនឹង ៤១,២៤%) ។ បច្ចុប្បន្ននេះ ក្រសួងអប់រំ យុវជន និង កីឡា កំពុងរិះរកវិធានការដើម្បីធានាបាននូវសមាមាត្ររវាងបុគ្គលិកបង្រៀន និងមិនបង្រៀនអោយបានល្អ ។




ចំនួនសិស្សបានកើនឡើងពី២.៤លាននាក់នៅឆ្នាំសិក្សា២០០០-០១ ទៅដល់ជាង២.៧លាននាក់ ក្នុងឆ្នាំសិក្សា ២០០២-០៣ ប៉ុន្តែបានថយចុះបន្តិចក្នុងឆ្នាំសិក្សា ២០០៤-០៥ អាស្រ័យដោយអត្រាកំណើនប្រជាជនក្នុងអំឡុង ៥ ទៅ ៦ ឆ្នាំកន្លងមកមានការថយចុះជាបន្តបន្ទាប់ ។

អត្រាពិតចូលរៀនថ្មីរបស់សិស្សបឋមសិក្សាក្នុងឆ្នាំសិក្សា ២០០៤-០៥ គឺ ៨១% ។ អត្រានេះទាបជាងដៅដែលបានគ្រោងទុកគឺ ៩០% ។ អត្រាពិតចូលរៀនថ្មីនៅថ្នាក់ទី ១ មានសារៈសំខាន់ណាស់ដែលគប្បីយកចិត្តទុកដាក់ខ្ពស់ពីព្រោះវាមានឥទ្ធិពលដល់ការវិភាគសំរាប់ពេលអនាគតលើការរៀនសូត្ររបស់ក្រុមសិស្សក្នុងវ័យជាមួយគ្នា ។ ចំណែកអត្រាពិតចូលរៀនថ្មីរបស់សិស្សស្រីមានចំនួន ៧៩% ធៀបនឹងដៅ ៩០% ។

អត្រាពិតនៃការសិក្សាសំរេចបាន ៩១.៩% ធៀបនឹងដៅក្នុងផែនការដែលគ្រោងទុក៩២% ។ អត្រាពិតនៃការសិក្សាសំរាប់សិស្សស្រីគឺ ៩០.៧% ធៀបនឹងដៅគឺ៩១% ។ ដៅអត្រាពិតនៃការសិក្សាសម្រាប់បឋមសិក្សាក្នុងឆ្នាំសិក្សា២០០៤-០៥ នៅតំបន់ក្រុងគឺ៩៥% តំបន់ជនបទ៩២% និងតំបន់ដាច់ស្រយាល៧៦% ។ តាមលទ្ធផលជាក់ស្តែងបង្ហាញអោយឃើញថា ការចូលរៀននៅបឋមសិក្សាក្នុងតំបន់ជនបទ និងតំបន់ដាច់ស្រយាលបានកើន លើសពីដៅដែលបានកំណត់ ប៉ុន្តែនៅតំបន់ទីប្រជុំជនបែរជាតិចជាងដៅទៅវិញ ។ បើប្រៀបធៀបនឹងឆ្នាំសិក្សា២០០០-០១ អត្រាពិតនៃការសិក្សាសរុបក្នុងឆ្នាំសិក្សា២០០៤-០៥នេះបានកើនឡើងជាង ២០%នៅតំបន់ដាច់ស្រយាល រីឯតំបន់ជនបទកើនបាន៨% ហើយនៅតំបន់ទីប្រជុំជន កើនបានប្រមាណតែ ៥%ប៉ុណ្ណោះក្នុងរយៈពេលដូចគ្នា ។




យើងអាចធ្វើការសន្និដ្ឋានបានថា ការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ បានជះឥទ្ធិពលជាវិជ្ជមានខ្លាំងក្លានៅតំបន់ជនបទនិងដាច់ស្រយាលដែលមានអ្នកក្រីក្ររស់នៅច្រើន បានច្រើនជាងនៅតំបន់ទីក្រុងឬទីប្រជុំជន ។

## ១.៣. មធ្យមសិក្សាបឋមភូមិ

ចំពោះមធ្យមសិក្សាបឋមភូមិ ក្រសួងអប់រំ យុវជន និងកីឡាក៏បានដាក់ចេញគោលនយោបាយ និង យុទ្ធសាស្ត្រដូចគ្នានឹងបឋមសិក្សាដែរ ។ ជាលទ្ធផលអនុវិទ្យាល័យបានកើនឡើងចំនួន ៩២កន្លែង ដែលក្នុងឆ្នាំសិក្សា២០០៤-០៥ មានចំនួន៥៧៨ ធៀបទៅក្នុងឆ្នាំសិក្សា២០០៣-០៤ មានត្រឹមតែ ៤៨៦សាលាប៉ុណ្ណោះ ។ ចំនួនសិស្សចូលរៀនសរុបមាន ៥២៨,៩៤០នាក់ ក្នុងនោះសិស្សស្រី មានចំនួន២៣០,០៤៨នាក់ ។



ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៤-០៨ បានកំណត់ដៅអត្រាពិតនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ សម្រាប់ឆ្នាំសិក្សា២០០៤-០៥ គឺតំបន់ក្រុង៥០% ក្នុងនោះស្រី៤៩% តំបន់ជនបទ៣៥% ស្រី៣៥% និងតំបន់ដាច់ស្រយាល១៥% ក្នុងនោះស្រី១៥% ។ ប៉ុន្តែតាមលទ្ធផលជាក់ស្តែងបង្ហាញអោយឃើញថា ការប្រមូលសិស្សចូលរៀននៅមធ្យមសិក្សាបឋមភូមិមិនសំរេចបានតាមការគ្រោងទុកទេ ទាំងតំបន់ក្រុង ជនបទ និង ដាច់ស្រយាល ។

បរិមាណសិស្សសាលាមធ្យមសិក្សាបឋមភូមិមានការកើនឡើងគួរអោយកត់សំគាល់ ។ សិស្សរៀនមធ្យមសិក្សាបឋមភូមិបានកើនពីចំនួន ២៣៣,២៧៨នាក់កាលពីឆ្នាំសិក្សា ១៩៩៩-២០០០ ទៅដល់ ៥២៨,៩៤០នាក់ក្នុងឆ្នាំសិក្សា ២០០៤-២០០៥។ នោះមានន័យថាចំនួនសិស្សកើនឡើង ១២៦% ក្នុងអំឡុងពេលខាងលើនេះ ។ អត្រាពិតនៃការសិក្សាគឺ២៦.១០% (ស្រី៩.៣០%) កើនខ្ពស់ជាងឆ្នាំសិក្សា ២០០៣-០៤ តែតិចជាងដៅ (៤០%)ជិតពាក់កណ្តាល ។

ទោះបីជាមានការពង្រីកសម្ភាររូបវ័ន្តសម្រាប់ថ្នាក់ទី៧ដល់ទី៩ នៅក្នុងឆ្នាំកន្លងទៅថ្មីៗនេះក៏ដោយក៏ពុំអាចឆ្លើយតបបានគ្រប់គ្រាន់ទៅនឹងតម្រូវការរៀនសូត្រនៅមធ្យមសិក្សាបឋមភូមិបានដែរ ពីព្រោះក្នុងចំណោមឃុំ១,៦២១ មានតែ៧៤៩ឃុំប៉ុណ្ណោះដែលមានសាលាមធ្យមសិក្សាបឋមភូមិ ។ ម្យ៉ាងទៀត អត្រាពិតនៃការសិក្សារបស់សិស្សនៅតំបន់ដាច់ស្រយាលមានកំរិតទាបបំផុតគឺ៣.៩% មានន័យថា កុមារវ័យជំទង់អាយុពី១២-១៤ឆ្នាំជាង៩៥% ពុំបានចូលរៀននៅមធ្យមសិក្សាបឋមភូមិទេដោយសារខ្វះសាលារៀន។



ជារួម ការអប់រំនៅមធ្យមសិក្សាបឋមភូមិមានដំណើរការជាប្រក្រតី បើទោះជាខ្វះគ្រូបង្រៀនតាមមុខវិជ្ជាឯកទេស តាមសាលារៀនខ្លះក្នុងតំបន់ជួបការលំបាក និងនៅក្នុងខេត្តដាច់ស្រយាលមួយចំនួនក៏ដោយ ។

ការងារគ្រប់គ្រងរបស់សាលារៀនមួយចំនួនធំមានប្រសិទ្ធភាព ដោយសារមានការចូលរួមពីសហគមន៍ តែនៅមានសាលារៀនដែលទើបបង្កើតថ្មីចំនួនប្រមាណ២០% នៅមានភាពរអាក់រអួលដោយអន្តើដែលបណ្តាលមកពីខ្វះបទពិសោធន៍ផង និងមិនបានឆ្លងវគ្គបំប៉ននាយកសាលារៀនផង ។ ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលពុំអាចប្រព្រឹត្តទៅបានល្អនៅតាមសាលារៀនមួយចំនួនធំ ដោយសារចំនួនសិស្សលើសនិយាមគរុកោសល្យ ខ្វះសៀវភៅសិក្សាគោល ខ្វះសម្ភារឧបទេស និងគ្មានបណ្ណាល័យ ។

ល្បឿននៃការរីកចម្រើនខ្លាំងខាងបរិមាណ នាំអោយគុណភាពអប់រំនៅមធ្យមសិក្សាបឋមភូមិស្ថិតក្នុងល្បឿនអភិវឌ្ឍន៍យឺត ពោលគឺបាត់តុល្យភាពរវាងការអភិវឌ្ឍផ្នែកបរិមាណ និងគុណភាព ។ តាមតួលេខស្ថិតិឆ្នាំសិក្សា២០០៤-២០០៥ នេះ ក្នុងចំណោមឃុំទាំងអស់ ១,៦២១ឃុំ មានឃុំចំនួន៨៧១ ទៀតដែលមិនទាន់មានអនុវិទ្យាល័យនៅឡើយ ។

## ១.៤. មធ្យមសិក្សាទុតិយភូមិ

ក្នុងឆ្នាំសិក្សា ២០០៤-០៥ វិទ្យាល័យសរុបមានចំនួន២៣២ ដែលឆ្នាំសិក្សា ២០០៣-០៤ មានតែ ២១២ប៉ុណ្ណោះ ។ សិស្សចូលរៀននៅមធ្យមសិក្សាទុតិយភូមិក្នុងឆ្នាំសិក្សា ២០០៤-០៥ មានចំនួនសរុប១៧៧,១២៩នាក់ ក្នុងនោះ សិស្សស្រីមានចំនួន៦៦,៣២៤នាក់ ។




អត្រាពិតនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិគឺ ៩.៣% និង ៧.៩% ចំពោះសិស្សស្រី ។ អត្រានេះមានការកើនឡើងខ្ពស់ជាងឆ្នាំសិក្សា២០០៣-០៤ក៏ពិតមែន ប៉ុន្តែមិនទាន់សម្រេចបានតាមដៅដែលគ្រោងទុកគឺ ១៥% សំរាប់

សិស្សសរុប និង ១៤%សំរាប់សិស្សស្រីនៅឡើយ ។ ពិនិត្យជារួម ការចុះឈ្មោះចូលរៀន មានការកើនឡើងតិចតួច បើធៀបនឹងឆ្នាំសិក្សា២០០៣-២០០៤កន្លងមក ដែលអាចបណ្តាលមកពីស្ថានភាពក្រីក្ររបស់ គ្រួសារសិស្ស ឬបណ្តាល មកពីតម្រូវការទីផ្សារពលកម្ម ឬដោយសារគ្មានអន្តេវាសិកដ្ឋានសម្រាប់សិស្សស្រីមកពីតំបន់ដាច់ស្រយាលជាដើម ។ មកទល់បច្ចុប្បន្ននេះ ក្នុងចំណោមស្រុកទាំង១៨៥នោះ មានស្រុកចំនួន៤៦ទៀតនៅមិនទាន់មាន វិទ្យាល័យនៅឡើយ ។




## ១.៥. ការងារអប់រំក្រៅប្រព័ន្ធ

ក្រសួងអប់រំ យុវជន និងកីឡា បានអនុវត្តសកម្មភាពអប់រំក្រៅប្រព័ន្ធតាមគ្រប់រូបភាពដូចជា ជំរុញកម្មវិធីសមាហរណកម្មសិស្សក្រៅប្រព័ន្ធអោយចូលរៀនក្នុងប្រព័ន្ធធម្មតាវិញ តាមរយៈការអនុវត្តកម្មវិធីចូលរៀនឡើងវិញ និង កម្មវិធីសមមូលដើម្បីបង្កឱកាសអោយសិស្សដែលបោះបង់ការសិក្សា រយៈពេល ១-៣ឆ្នាំ ហើយនោះបានចូលរៀនក្នុង ប្រព័ន្ធអប់រំចំណេះទូទៅឡើងវិញ ។

នៅកម្ពុជា អត្រាអក្ខរកម្មមនុស្សពេញវ័យចាប់ពី ១៥ឆ្នាំឡើងគឺ ៦៧.៣% ។ ក្រសួងបានខិតខំជំរុញការងារ អក្ខរកម្មតាមរយៈការបើថ្នាក់អក្ខរកម្មដើម្បីរំដោះប្រជាជនពីគ្រោះមិនចេះអក្សរ និងការផ្តល់កម្មវិធីក្រោយអក្ខរកម្ម តាមរយៈការបង្កើតមជ្ឈមណ្ឌលសិក្សាសហគមន៍ ដើម្បីទប់ស្កាត់គ្រោះភ្លេចអក្សរផង និង ពង្រឹងចំណេះដឹងបំណិនជីវិតផង ដើម្បីអាចឈានទៅទទួលកម្មវិធីបង្កើនប្រាក់ចំណូលនិងជំនាញវិជ្ជាជីវៈងាយៗ ដោយសហការល្អជាមួយអង្គការក្រៅ រដ្ឋាភិបាល និង អង្គការអន្តរជាតិនានា ។ ជាមួយនោះ កម្មវិធីអប់រំក្រៅប្រព័ន្ធក៏បានផ្តល់លទ្ធភាពអោយមនុស្សពេញវ័យ ដែលគ្មានជំនាញ ពិសេសអនក្ខរជន និងយុវជននៅក្រៅសាលារៀន បានចូលរៀនក្នុងកម្មវិធីអក្ខរកម្មវិជ្ជាជីវៈ ។

ជាមួយនោះដែរ ក្រសួងអប់រំ យុវជន និងកីឡា បានសហការជាមួយអង្គការក្រៅរដ្ឋាភិបាលនានា ដើម្បីជួយដល់ការងារអប់រំក្រៅប្រព័ន្ធអោយមានដំណើរការល្អទាំងផ្នែកបរិមាណនិងគុណភាព ។ ជាក់ស្តែង ក្រសួងកំពុងខិតខំបង្កើតអោយមានប្រព័ន្ធពត៌មានគ្រប់គ្រងការងារអប់រំក្រៅប្រព័ន្ធ ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីនានាដែលអាចជួយដល់កុមារ-សិស្សក្រៅសាលារៀន និងយុវជន ព្រមទាំងជនពេញវ័យនៅតាមមូលដ្ឋានដែលពុំទាន់ មានជំនាញងាយៗដើម្បីជួយបង្កើនប្រាក់ចំណូលរបស់គ្រួសារ ។

## ១.៦. ឧត្តមសិក្សា

ក្នុងឆ្នាំសិក្សា ២០០៤-០៥ គ្រឹះស្ថានសិក្សាឧត្តមសិក្សាសរុបមានចំនួន ៤៤ ដែលក្នុងនោះ គ្រឹះស្ថានសិក្សារបស់រដ្ឋមានចំនួន ១៣ និងគ្រឹះស្ថានសិក្សាឯកជនមានចំនួន ៣១ ។ បច្ចុប្បន្ននេះ គ្រឹះស្ថានឧត្តមសិក្សា និងសាខាដែលភាគច្រើនលើសលប់ជាគ្រឹះស្ថានឯកជន បានបើកដំណើរការនៅតាមបណ្តាខេត្ត-ក្រុងនានាចំនួន ១១ ។ គ្រឹះស្ថានសិក្សា និងសាខាទាំងអស់នេះ បានផ្តល់កាលានុវត្តភាពដល់សិស្ស-និស្សិត ដែលរស់នៅតាមខេត្ត-ក្រុងទាំងនោះ បានបន្តការសិក្សាទៅថ្នាក់ឧត្តមសិក្សាជាបន្តទៀត ។







រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយឯកជនភាវូបនីយកម្ម ដែលធ្វើអោយមានផលប៉ះពាល់ជាវិជ្ជមានដល់ការងារអប់រំនៅកំរិតឧត្តមសិក្សា ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ គ្រឹះស្ថានសិក្សាឯកជនបានជួយសំរាលបន្ទុកយ៉ាងច្រើនក្នុងការទទួលសិស្សចូលរៀន ក៏ដូចជាជួយកាត់បន្ថយចំនួនសិស្សចូលរៀននៅគ្រឹះស្ថានសិក្សាសាធារណៈ ។ ជាក់ស្តែងនិស្សិតរៀនបង់ថ្លៃក្នុងឆ្នាំសិក្សា២០០៤-០៥ តាមគ្រឹះស្ថានឧត្តមសិក្សាមានចំនួន ៣៨,៧២២នាក់ ។

ទន្ទឹមនោះ ក្រសួងអប់រំ យុវជន និងកីឡា បានខិតខំបង្ករលក្ខណៈសម្បត្តិសមស្របក្នុងការចូលរៀននៅឧត្តមសិក្សា ដើម្បីលើកកម្ពស់ការកសាងធនធានមនុស្សប្រកបដោយគុណភាពសំរាប់អនាគតរបស់ប្រទេសជាតិ ។ ក្រសួងបានផ្តល់អាហារូបករណ៍ដល់សិស្ស/និស្សិតដែលរៀនពូកែ និស្សិតក្រីក្រ និស្សិតជានារីភេទ និងនិស្សិតមកពីតំបន់ដាច់ស្រយាលជាពិសេស បានខិតខំជំរុញការសាងសង់អន្តេវាសិកដ្ឋានសម្រាប់និស្សិតក្រីក្រ និងនិស្សិតជានារីភេទ ។

## ១.៧. ការងារបណ្តុះបណ្តាលគ្រូបង្រៀន

តាមស្ថិតិក្នុងរយៈពេលពីរឆ្នាំសិក្សាចុងក្រោយនេះបង្ហាញឱ្យឃើញថា នៅឆ្នាំសិក្សា ២០០៣-០៤ ចំនួនគរុសិស្ស-និស្សិតទទួលការបណ្តុះបណ្តាលនៅតាមសាលាគរុកោសល្យនិងវិក្រឹតការខេត្ត-ក្រុង មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងមជ្ឈមណ្ឌលគរុកោសល្យមត្តេយ្យមជ្ឈឹមទាំងអស់មានចំនួន ៨,៦៧១នាក់ ។ ចំណែកឆ្នាំសិក្សា២០០៤-០៥ ចំនួនគរុសិស្ស-និស្សិតដែលកំពុងទទួលការបណ្តុះបណ្តាលនៅតាមសាលាគរុកោសល្យនិងវិក្រឹតការខេត្ត-ក្រុង មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងមជ្ឈមណ្ឌលគរុកោសល្យមត្តេយ្យមជ្ឈឹមទាំងអស់មានតែ ៦,៥២០នាក់ប៉ុណ្ណោះ ។ ដូច្នេះចំនួនគរុសិស្ស/និស្សិតបានថយចុះដល់ទៅ ២៤.៨% ដោយសារការកាត់បន្ថយបរិមាណជ្រើសរើសគរុសិស្ស-និស្សិតសម្រាប់បណ្តុះបណ្តាលក្នុងឆ្នាំសិក្សាកន្លងមក ។ ករណីនេះ អាចចាត់ទុកថាជាមូលហេតុនៃការខ្វះគ្រូបង្រៀន ដែលចាំបាច់ត្រូវដោះស្រាយឱ្យបានឆាប់រហ័ស ដើម្បីឈានទៅសម្រេចគោលដៅអប់រំសម្រាប់ទាំងអស់គ្នានៅឆ្នាំ ២០១៥ ។




តារាងខាងក្រោមនេះបង្ហាញអោយឃើញពីស្ថានភាពគរុសិស្ស-និស្សិត នៅតាមសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈឹម សាលាគរុកោសល្យ និងវិក្រឹតការខេត្ត-ក្រុងទាំង ១៨ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគទាំង ៦ និងវិទ្យាស្ថានជាតិអប់រំ ។

*តារាងទី១ : ចំនួនគរុសិស្ស-និស្សិតនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ*

| គ្រឹះស្ថានបណ្តុះបណ្តាល | លទ្ធផលជាក់ស្តែង ២០០៣-០៤ | | លទ្ធផលជាក់ស្តែង ២០០៤-០៥ | | ដៅ ២០០៤-០៥ | | ភាគរយសំរេចបាន (%) | |
|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| សរុប | ៨,៦៧១ | ៣,១៧១ | ៦,៥២០ | ២,៥១២ | ១២,០០០ | ៤,៣០០ | ៥៤.៣៣ | ៥៨.៤២ |